

# ចុះបើសិនជា?

Hari Kumar Nair

Hari Kumar Nair

letsreadasia.org



ខ្ញុំឈ្មោះ ស៊ីយ៉ាម។ ខ្ញុំមាន
អាយុ១០ឆ្នាំ។ ខ្ញុំមានរូបរាងស្គមបន្តិច
តែខ្ញុំក្លាហានណាស់។ ក្រោកពីគេង
រាល់ថ្ងៃដើម្បីទៅសាលា មិនសប្បាយ
សោះ។ ពេលខ្ញុំក្រោកពីគេង ខ្ញុំនៅ
ងងុយគេងខ្លាំងណាស់ រហូតដល់ខ្ញុំ
គិតថាខ្ញុំអាចដើរដួល។



ភ្នែកខ្ញុំបិទ ពេលដែលខ្ញុំកំពុង
ដុសធ្មេញ។ ខណៈនោះ ខ្ញុំឮសំឡេង
ម្ដាយខ្ញុំកំពុងតែប្រញាប់ប្រញាល់
ធ្វើម្ហូប។ អារម្មណ៍របស់ខ្ញុំចាប់ផ្ដើម
រវើរវាយ ហើយខ្ញុំចាប់ផ្ដើមគិតប្លែកៗពី
រឿងជាច្រើន។



ចុះបើសិនជា ករបស់ខ្ញុំ វែងជាង
នេះ១០ដង? ក្បាលខ្ញុំនៅសាលា ហើយ
ខ្លួនខ្ញុំនៅផ្ទះដែលជាកន្លែងខ្ញុំចង់គេង?



ចុះបើសិនជា ជើងរបស់ខ្ញុំវែងដូចជាដើមឈើ? សាលារៀនមានកម្ពស់ត្រឹមជង្គង់របស់ខ្ញុំ!



ចុះបើសិនជា ដៃរបស់ខ្ញុំ មានកម្លាំងខ្លាំង? ខ្ញុំប្រាកដជាអាចលើកម្ដាយខ្ញុំបានយ៉ាងងាយ។



ចុះបើសិនជា ធ្មេញរបស់ខ្ញុំអាចទំពាអាហារបានគ្រប់មុខទាំងអស់? ខ្ញុំនឹងញ៉ាំគ្រប់អាហារដែលខ្ញុំចង់ញ៉ាំ!



ចុះបើសិនជា ពោះរបស់ខ្ញុំមូលធំខ្លាំង?
មិត្តភក្តិរបស់ខ្ញុំអាចហក់លោតលេងលើ
ពោះខ្ញុំបាន!



ចុះបើសិនជា ត្រចៀករបស់ខ្ញុំធំដូច
ត្រចៀកដំរី? ខ្ញុំនឹងអាចស្តាប់ឮអ្វីៗ
គ្រប់យ៉ាងទាំងជិតទាំងឆ្ងាយ។



ចុះបើសិនជា???....រំពេចនោះ ម៉ាក់របស់ខ្ញុំស្រែកថា ’ស៊ីយ៉ាម យឺតម៉ោងទៅសាលាហើយ តើកូនកំពុងគិតអ្វីហ្នឹង?’



ពេលនោះ ខ្ញុំភ្ញាក់ខ្លួនព្រើត ខ្ញុំកំពុងតែកាន់ច្រាសដុសធ្មេញនៅឡើយ។ ខ្ញុំញញឹម បន្ទាប់មកទៀតខ្ញុំក៏ស្រមើស្រមៃបន្តទៀត។

Brought to you by

The Asia Foundation

Let's Read! is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia. booksforasia.org

To read more books like this and get further information about this book, visit letsreadasia.org

Original Story
What If?, author: Hari Kumar Nair . illustrator: by Hari Kumar Nair. Published by Pratham Books, https://storyweaver.org.in/stories/880-what-if © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Sivngim Nguon